# ១១. រឿង សុភាទន្សាយ

ពាក្យកាព្យ បទមណ្ឌោកគតិ

នេះនឹងស្រដី ពីសត្វប្រាំនែហោងណា ភេមាន់អកខ្លា និងទន្សាយទាំងប្រាំជាក់ ។ គិតគ្នាធ្វើផ្ទះ នឹងបានប្រើប្រាស់ទុកដាក់ គ្រាន់បានសម្នាក់នឹងបានគិតការតទៅ ។ ខ្លាថាបើច្នោះ ព្រមគ្នាចំពោះឥឡូវ យើងទៅច្រូតស្បូវ រួចហើយសឹមយើងគិតសង់ ។ គិតស្រេចហើយណា បបួលគ្នីគ្នាដើរត្រង់ពុំហ៊ានបង្អង់ ពុំបានឈរឈប់ទ្បើយណា ។ ដើរទៅដល់ព្រៃ គយគន់រំពៃព្រឹក្សាឃើញវាលស្បូវណា នេះហើយគេហៅស្បូវល្អ ។ ដល់បោះជំរំ និយាយគ្នាជុំមាត់កថានេះស្បូវល្អ យើងរកទៅទៀតក្រែងគ្មាន ។ យើងច្រូងរៀងអាយ ទោះក្រទោះងាយគង់បាន ទៅទៀតក្រែងគ្មាន ពុំបានប្រទះស្បូវល្អ ។ គេថាឥឡូវ ឲ្យអ្នកបងខ្លានៅអាយ ចាំដៃឲ្យបាយ រៀបស្លដណ្ដាំឲ្យស្រេច ។ ថាហើយនាំគ្នាដើរទៅម្នីម្នារំពេច ដល់ទៅព្រៃស្រេច ទន្សាយថាគ្នាយើងអើយ ។ យើងច្រូតនៅនេះ ទៅឆ្ងាយម្ដេចម្ល៉េះអ្នកអើយ ស្បូវច្រើនម្ល៉េះហើយ នេះឯងហៅស្បូវល្អណាស់ ។ ភេអកនូវមាន់ ព្រមគ្នារួសរាន់រហ័ស ច្រូតស្បូវឆាប់ណាស់ តែមាន់និងអកនូវភេ ។ ឯអាទន្សាយ រកកលនាយអាយវេះវេ ភៀសប្រាប់ទៅគេ ថារ៉ុអើយគ្នាឈឺពោះ ។ តែវាធ្វើកល កិច្ចដោយយោបល់វានោះ វាថាឈឺពោះ តែវាចង់ទៅមើលខ្លា ។ វាដើរឆ្លៀតឈ្លប តិចៗលលបម្នីម្នា ជូនប្រទះខ្លា លោតចាប់ឯក្ដាន់នោះបាន ។ ក៏ឃើញជាក់មិញ រត់ទៅឃ្មាតខ្មាញ់ដោយដាន ដៃឱបខ្លួនប្រាណ វាធ្វើជាគ្រុនញញ័រ ។ ដៃមួយស្ទាបពោះ វាដើរទៅនោះទទ័រ ញញីញញ័រ វាធ្វើឲ្យគេជឿហោង ។ ភេមាន់នូវអក ឃើញដណ្ដឹងមកអឹងកង ហើយជេររំពង អាចោរម្ដេចអាព្រងើយ ។ មិនច្រូតស្បូវ ម្ដេចអាលេងនៅកន្ដើយ ឱបដៃព្រងើយ ដើរលេងសព្វព្រៃព្រឹក្សា ។ ទន្សាយឆ្លាស់ឆ្លើយ ថាឱអ្នកអើយអស់គ្នា កុំអាលផ្ដាសា ចាំខ្ញុំដំណាលប្រាប់អ្នក ។ អ្នកអើយខ្ញុំគ្រុន ស្ទើរស្លាប់ប៉ប្រុនញ័រញាក់ ពោះខ្ញុំឈឺចាក់ ដោតហើយចុះផ្ទៃខ្ញុំផង ។ វាឈឺបោះខ្ទាញ់ ដូចគេត្របាញ់ណាស់ហោង អាសូរខ្ញុំផង ខ្ញុំមិនមានពុតទេណា ។ ភេមាន់នូវអក ឮវាប្រាប់មកសោះសា មិនស្រដីថា ទៅវិញទៅមកទ្បើយនែ ។ ច្រូតស្បូវតិចទៅ ទន្សាយនោះកូវស្រដី ថារ៉ុអើយរ៉ុ ដល់យើងនឹងទៅល្ងាចណា ។ យើងបានត្រីសាច់ ខ្លះទេបន្តិចអាហារ គ្រាន់បរិភោគ្គា នោះមានឬទេអ្នកអើយ ។ ទន្សាយថាបើ ដោយយាមអញមើលជាត្រើយ ដល់ទៅល្ងាចហើយ ប្រាកដជាមានលាភជ័យ ។ ភេមាន់អកខ្លា បើច្នោះលងអាទាយនែ ឲ្យប្រាកដក្រៃ ឥឡូវនេះ លងមើលអា ។ ទន្សាយឆ្លាស់ឆ្លើយ ថាឱអ្នកអើយគ្រប់គ្នា ដល់យើងទៅណ៎ាប្រាកដជាបានសាច់ក្ដាន់ ។ បើអញទាយត្រូវ ប្រាកដដូច្នោះកូវដាក់ស្បាន់ ថាបានសាច់ក្ដាន់អស់អ្នកកុំស៊ីទ្បើយណ៎ា ។ ភេមាន់អកនែ ថាអើនែរ៉ុយើងប្រាកដមិនស៊ីណ៎ា យើងឲ្យតែអាស៊ីហោង ។ លុះល្ងាចនាំគ្នាដើរមកម្នីម្នាត្រសង ដល់ដៃហើយហោង ហើយដណ្ដឹងទៅបងខ្លា ។ ថានែអ្នកបង អ្នកបានអ្វីហោងជាអាហារបរិភោគ្គា ខ្លះទេឬគ្មានទ្បើយនែ ។ ខ្លាឆ្លើយប្រាប់មក ថាអញទៅរកក្នុងព្រៃបានក្ដាន់មួយនែ យកមកចម្អិនហើយណ៎ា ។ ទន្សាយស្ដាប់ជាក់ ថារ៉ុយអស់អ្នកគ្រប់គ្នា មែនដូច្នេះណ៎ា ថាឯងមិនស៊ីទ្បើយហោង ។ ឥឡូវមែនហើយ ឯងកុំស៊ីទ្បើយជាម្ដង សាច់នោះឯងហោង អញស៊ីតែនឹងបងខ្លា ។ ភេមាន់អកនោះ ស្ដាប់ហើយទ្រគោះសោះសា ជេរថាប៉ែអាដកទងចោរខូចក្រៃលែង ។ ថ្វីបើយើងស៊ី យើងមិនសុំជីដូនឯង អាកុហកខូចឯង រងតែកំភូតមាយា ។ រីអ្នកទាំងប្រាំបរិភោគហើយនាំគ្នីគ្នា ដេកលុះព្រឹកណ៎ា ហើយមកគិតគ្នាទៀតនែ ។ ថ្ងៃនេះយើងចង់ ឲ្យភេចាំរង់នៅដៃ យើងទាំងបួននែ នឹងទៅច្រូតពីព្រឹកហោង ។ គិតស្រេចហើយណ៎ា នាំគ្នាយាត្រាជាម្ដង ៗ បានឆ្ពោមកស្ល ចាំរង់អស់គ្នាច្រូតស្បូវ ។

ទន្សាយនោះណ៎ា ច្រូតបានតិចវាវេះទៅ លបមើលភេកូវ ឃើញភេចាប់បានឆ្តោជាក់ ។ ឃើញហើយវិលទៅ ខ្លាអក មាន់ទៅភ្ញាភ្ញាក់ អាចោរអប្បលក្ខណ៍ អាខូចអាទៅណា ។ ទន្សាយឆ្លាស់ឆ្លើយ ដូចពីដើមឡើយសោះសា អស់ត្រង់ នេះណ៎ា ដូចយើងស្រដីមុនហើយ ។ ត្រង់ចេះទាយហោរ ដូចពីមុនមកអ្នកអើយ ពុតមិនបាត់ឡើយ ត្រង់វេះត្រង់វេរ មិនបាត់ ។ ច្រូតលុះល្ងាចមក ឮមាត់រឱកពុំស្ងាត់ មកដល់ពុំបាត់ ញ៉ូរញ៉ាក់ដណ្តឹងទៅភេ ។ ថាអ្នកចាំជៃ បានម្ហូប ចំណីឬទេ នោះទើបឯភេ ប្រាប់មកថា បានត្រីឆ្តោ ។ ទន្សាយស្តាប់ជាក់ ហើយថា អស់អ្នកកោតហោរ អញចាប់ដៃរក៏ ឥឡូវប្រាកដមែនណ៎ា ។ អស់នេះយើងបាន ស្រដីមែនមានមកប្រាកដពីដើមណ៎ា ដំណើរសឹងដូចគ្នាហោង ។ អស់ អ្នកទាំងប្រាំ ស៊ីបាយហើយនាំគ្នាផង ដេកដល់ព្រឹកហោង មកគិតនឹងគ្នាទៀតនៃ ។ ថ្ងៃនេះយើងឲ្យ បងអកចាំគយ នៅជៃ អស់យើងទៅព្រៃ ទាំងបួននាក់នោះហងណ៎ា ។ គិតហើយលីលា ដើរទៅម្ទីម្នាសោះសា ដល់ស្បូវច្រូតណ៎ា ដល់តិចទន្សាយវេះធ្លាប់ ។ ក្រោយនោះបងអក គាត់ទៅសំកុកចាំចាប់ ត្រីប្រាបានខ្ជាប់ រួចហើយទើបយកមកស្ល ។ ទន្សាយឆ្លៀតឈ្លប ដើរមកលលបដក-ក មើលដាក់ហើយចរ លីលាវិញទៅជាម្តង ។ ដំណើរនេះនៃ ដូចយើងស្រដី ដើមហោង ពុតណាស់កន្លង ត្រង់ហោរនោះ ដូចដើមណ៎ា ។ លុះល្ងាចលើលា ដើរមកថ្មីម្នាសោះសា ដណ្តឹងអកថា អ្នកតែងចាំជៃនោះហោង ។ បងអើយបងអក ឥឡូវយើងជាម្តង បងបានអ្វីហោង គ្រាន់ស៊ីជាម្ហូបឬទេ ។ អកឆ្លាស់ ឆ្លើយប្រាប់ ទៅគេឆាប់ៗថាទេ ខ្លាចក្រែងតែគេ នៅពុំដូចអញនេះហោង ។ ឥឡូវអញបាន ប្រាមួយមកមានជាម្តង ចម្អិនហើយហោង ទុកឲ្យអស់អ្នករាល់គ្នា ។ ទន្សាយស្តាប់ជាក់ ថាអស់អ្នករាល់គ្នា អញទាយនេះណ៎ា ថាបានត្រីប្រា ស៊ីហោង ។ ដំណើរទន្សាយ ពុតខូចរាយមាយកន្លង ដូចពីដើមហោងរៀងរាបនោះមកឯងណ៎ា ។ អស់អ្នកទាំងប្រាំ ស៊ីបាយហើយនាំគ្នីគ្នា ដេកលក់ព្រឹកណ៎ា គិតគ្នារឱកអឹងកង ។ ថ្ងៃនេះឯងនៃ ឲ្យមាន់ចាំជៃនោះហោង ហើយទាំងបួន ផង ទៅរកច្រូតស្បូវហោងណ៎ា ។ ច្រូតបន្តិចទៅទន្សាយនោះ កូវលីលា វេះបាត់ហើយណ៎ា មកឈ្លបចាំមើលមាន់ ហោង ។ រីឯមាន់នោះ គិតចប់ក្នុងពោះកន្លង គេចាំជៃផង គេបានសាច់ស៊ីផងណ៎ា ។ ឥឡូវនេះអញ មានតែពងពេញ ជាអាហារបរិភោគ្គា ទុកឲ្យអស់គេស៊ីផង ។ គិតហើយរមាត់ ពងធ្លាក់ចេញថ្ងាត់ជាម្តង យកមកស្ងោរហោង ទុកឲ្យ អស់អ្នកគ្នីគ្នា ។ ទន្សាយឆ្លើយឈ្លប ប្រួញខ្លួនលលបមើលណ៎ា យល់ឃើញជាក់ប្រាកដដូច្នោះហើយវិលទៅ ។ ដំណើរទន្សាយ ពុតខូចរាយមាយនោះ កូវត្រង់ពាក្យអាស្រូវ នោះភូតមិនបាត់ឡើយណ៎ា ។ ដំណើរនេះហោង អស់ ទាំងអ្នកផងគ្រប់គ្នា ដឹងអស់ពុតវា អាខូចកុហកវេះហោង ។ លុះល្ងាចនោះកូវ អស់អ្នកច្រូតស្បូវជាម្តង លីលាមក ហោង ដល់ហើយដណ្តឹងមាន់ថា ។ ថាអ៊ើយបងមាន់បានអ្វីនោះគ្រាន់ស៊ីជា អាហារភោគ្គា ខ្វះទេឬគ្មានឡើយហោង ។ មាន់ថាអញបាន ពងស្ងោរនៅក្រានជាម្តង អ្នកកុំគិតហោង ត្រង់ម្ហូបនោះឯងឡើយណ៎ា ។ ទន្សាយស្តាប់ជាក់ ថា ឱអស់អ្នកគ្រប់គ្នា ហោរអញឆុតណ៎ា ប្រាកដដូចអញថាហោង ។ ដំណើរទន្សាយ ពុតខូចរាយមាយកន្លង ពុំលែង អស់ផង ដូចយើងស្រដីដើមណ៎ា ។ អស់អ្នកទាំងប្រាំ ស៊ីបាយរួចនាំគ្នីគ្នា ដេកលុះព្រឹកណា ទៅរកច្រូតស្បូវអឹងកង ។ ថ្ងៃនេះឯងនៃ ទន្សាយចាំជៃវិញម្តង យើងបួននាក់ផង នោះទៅច្រូតស្បូវហោងណ៎ា ។ គិតស្រេចដើរទៅ ទន្សាយនោះ កូវវាជា ទុកក្រែមហិមា ព្រួយចិត្តនឹងខ្លួនពេកក្រៃ ។ នឹងរកអ្វីជា គ្រាន់ជាអាហារចំណី សង្វាតចាំជៃ រកអ្វីជាម្ហូបគ្មាន ឡើយ ។ ទន្សាយគិតឆ្ងល់នឹកទៅមិនយល់សោះឡើយ ថាឱអញអើយ អញបានអ្វីជាម្ហូបអ៊ា ។ បើច្នោះអញល្បង ធ្វើ តាមទំនងបងខ្លា លបចាប់ក្តាប់ណ៎ា គ្រាន់បាននឹងយកមកស្ល ។ ទន្សាយគិតច្នោះ ដើរទៅពួនឆ្តោះធ្វើ-ក លឹបលជាក់ ល្អ ប៉ុនប៉ងលបមើលទៅក្តាន់ ។ ពួនបន្តិចទៅ ឃើញសត្វនោះកូវដាក់ស្បាន់ ពានលើសត្វក្តាន់ ទន្សាយរឹងព្រួយអាត្មា

។ ក្ដាន់ដើរជិតមក ទន្សាយចាប់យកសោះសា ក្ដាន់វាវែធណ៎ា ទន្សាយនោះដួលផ្កាប់មុខ ។ ទន្សាយដោះឡើង ពេញ មុខស្រមើងពន្លក់មើលមុខអាក្រក់ ហើយលាន់មាត់ឯងថាអុះ ។ អញម្ដងនេះណ៎ា ស្លាប់បង់អាសាខ្លួននោះ ឈឺចាក់ពុងពោះ វាខ្លោចវាផ្សារពេកក្រៃ ។ ឆ្អឹងឆ្អែងស្ទើរបាក់ ខ្នាំគ្រាំញញក់ណាស់នៃ ឈឺពោះឈឺផ្ទៃ ឈឺសព្វសរសៃពេកណ៎ា ។ ទន្សាយកំហូច ចំណេះបង្ខូចខ្លួនវា អាចោរប៉ែអា ខ្លួនប៉ុនកដៃចាប់ក្ដាន់ ។ រួចពីនោះទៅ ទន្សាយនោះកូវវាកាន់កែគិតរន្ធាន់ ព្រួយចិត្តក្រៃងគ្មានម្ហូបស៊ី ។ ទន្សាយនោះកូវ ធ្វើមុខកញ្ជូរ ម្នាម្នី ធ្វើត្រាប់ភេខ្មី ទៅរកមុជទឹកគយរ ។ មុជ ដល់ទៅដី លោចាប់បានត្រីខ្ជាប់ល្អត្រីវានាំជ្រ- មុជទៅយូរពេកណាស់ក្រៃ ។ ថប់ហើយក្រៃងត្រី ស្ទើរផុតជីវីក្សិណក្ស័យ ភ្នែកនោះសក្រៃ ហាក់ដូចជាមុខខ្មោចណ៎ា ។ ឡើងមកក្រញោន ធ្វើខ្លួនកុំប្រោនដូចស្វា មុខមាត់ជ្រីវណា រងាញញ័រជើងដៃ ។ អង្គុយយូរទៅ មានកម្លាំងកូវហើយនៃ ព្រួយចិត្តពេកក្រៃ ត្បិតមិនបានម្ហូបហោង ។ អស់គេនោះណ៎ា គេនៅបានអាហារផង ស៊ីមិនអស់ហោង វាខូចតែអញពេកណ៎ា ។ អះបើច្នោះអញ នឹងទៅទៀតមិញសោះសា ត្រាប់ បងអកណ៎ា ក្រៃងលោបានដូចអកធ្វើ ។ គិតដូច្នេះហើយ ដើរទៅកន្ទើយរកឈើ ឡើងសំកុកលើ ដូចអកនោះឯង ហោងណ៎ា ។ ត្រីបន្លៀកទន្សាយលោតតួងសោះសា ចាប់បានហើយណ៎ា ត្រីនាំរត់ទៅទៀតហោង ។ យូរទៅបន្តិច វា ថប់ស្ទើរដាច់ខ្យល់ផង លែងត្រីជាម្ដង ឡើងទៅអង្គុយមាត់ច្រាំង ។ ភ្នែកវា-សល្អក់ មើលមុខអាក្រក់ស្រឡាំងកាំង សម្បុរសស្លាំង ហាក់ដូចជាមុខខ្មោចព្រាយ ។ ហើយរងាញ័រ ទទីទទ័រអង្គកាយ ញ័រអស់សព្វសាយ រណ្ដំទាំងធ្មេញកខុប ។ ឱអញអើយអញ មួយដងនេះមិញស្ទើរស្លាប់ បើស្លាប់ឲ្យឆាប់ កុំឲ្យលំបាកច្នេះនៃ ។ ពីនេះតទៅ ទន្សាយនោះ កូវប្រែវៃ គិតវិញទៀតនៃ បើច្នោះអញត្រាប់មាន់ណ៎ា ។ គិតហើយទៅយក ឆ្នាំងសម្លមកម្នីម្នា យកមកហើយណ៎ា ទើប វារៀបខ្លួនប្រាណណា ។ វាយកឆ្នាំងមក ប្រឹងជុះបញ្ជ្រកឆ្នាំងបាន កន្លះមែនមាន យកទៅចម្អិនស្រេចការ ។ ចម្អិនរួច ស្រេច ហើយវាក្រឡាប់ម្នីម្នា ដេកធ្វើដូចជា គ្រុនញាក់ញញីញញ័រ ។ អស់អ្នកច្រូតស្បូវ លុះល្ងាចមកកូវទទ័រ ដណ្ដឹង ញញ័រ ថាវ៉ឺយអើយបងទន្សាយ ។ ឯងបានរបស់អ្វី ធ្វើម្ហូបចំណីស៊ីបាយ រីឯទន្សាយធ្វើជាញ័រមាត់ឆ្លើយវៃ ។ ថាឱអ្នក អើយ ខ្ញុំនេះគ្រុនហើយណាស់នៃ ស្ទើរស្លាប់ពេកក្រៃ ខ្ញុំមិនបានម្ហូបអ្វីឡើយ ។ ខ្ញុំខំបន្ទោះប្រហុកនៅនោះអ្នកអើយ ឆ្អិនរួចអស់ហើយ ចូរអ្នកនាំគ្នាស៊ីហោង ។ អ្នកទាំងបួននោះ មិនដឹងខ្លួនសោះជាម្ដង ជឿទន្សាយហោង ថាជាប្រហុក មែនណ៎ា ។ នាំគ្នារចល់ស៊ីបាយរវល់ គ្រប់គ្នាខ្លះហៅវ៉ឺយអា ទន្សាយមកស៊ីឬទេ ។ ទន្សាយឮជាក់ ធ្វើជាញ័រញាក់ ប្រាប់គេថាឱមេ ៗ គ្នាគ្រុនគ្នាស្រៀវណាស់ហោង ។ ចូរអ្នកស៊ីចុះ ទាំង៤នាក់នោះជាម្ដង កុំថាអញហោង អញនេះឈឺខ្លាំងណាស់នៃ ។ ភេមាន់អកខ្លា បបួលគ្នីគ្នាវៃ ៗ ស៊ីបាយរួចនៃ ទាល់ឆ្អែតមិនដឹងខ្លួនសោះ ។ ឯអាទន្សាយ ពុតខិល វាយមានខូចស្មោះ ដល់គេស៊ីអស់ រួចគាត់ដោះឡើយឆាប់ផាង ។ គាត់ឈរហើយស្ទឹម ចង្កេះញញឹមក្អេងក្អាង ថាវ៉ឺយអាឃ្នាង ម្ដេចអាមកស៊ីអាចម៍អញ ។ ភេមាន់អកខ្លា ភ្ញាក់ខ្លួនគ្រប់គ្នាហើយក្នាញ់ ជាទុក្ខទោម្នេញ គ្រប់គ្នាទីទៃពេកណ៎ា ។ ថាវ៉ឺយគ្នាយើង ចូរឯងឆាប់ឡើងម្នីម្នា ដេញវាយប៉ែអា ដកទងចោរខូចនេះហោង ។ ម្ដេចអាកុហក ឲ្យយើង ស៊ីលាមកជាម្ដង នៃវ៉ឺយឆាប់ហោង ដេញវាយអាចោរនេះណ៎ា ។ ថាហើយដេញទៅ ទន្សាយនោះកូវមិញវា ចូលព្រៃ ព្រឹក្សា រកពុំឃើញវាឡើយនៃ ។ ទាំងអស់គ្នាដេញ មិនទាន់វិលវិញវៃ ៗ វិលមកឆាប់ព្រៃ ដល់ហើយអង្គុយជុំគ្នា ។ ទន្សាយនោះនៃ រត់ចូលក្នុងព្រៃសោះសា វិលមកវិញណ៎ា នៅជាមួយគ្នាឯងហោង ។ ភេមាន់អកខ្លា ឃើញទន្សាយ មកជាម្ដង រសាយខឹងហោងយកវាជាគ្នាវិញណា ។ បទពំនោល

កាលនោះភេមាន់ខ្លា ទន្សាយនោះណា ច្រូតស្បូវបានសព្វគ្រប់ហោង ។ ហើយមកគិតគ្នាអឹងកង ធ្វើម្ដេចរួចហោង ដឹកស្បូវទៅផ្ទះយើងណ៎ា ។ ទន្សាយវាធ្វើទៅថា មានតែបងខ្លា ខ្លួនគាត់នេះធំល្អណាស់ ។ ភេស្ដាប់ទន្សាយឆ្លើយ ឆ្លាស់ ធ្វើថាគួរណាស់ ខ្លាគាត់មានមាឌធំល្អជា ។សមនឹងអូសស្បូវយើងប្រា- កដមិនទេណ៎ា ខ្លានោះឥតប្រកែក ឡើយ ។ ទើបរករៀបផ្ទុកស្បូវហើយ ឥតមានសល់ឡើយ ដាក់លើខ្នងខ្លានោះនែ ។ អ្នកខ្លះស្រែកទៅថារ៉ុ យកចាន ក្បានថ្មី នូវអស់វែកឆ្នាំងនោះណ៎ា ។ យកមកដាក់លើខ្នងខ្លា ឆាប់ឡើងម្ទីម្ទា ហើយយកដែកភ្លើងមកផង ។ រៀបស្រេច ហើយមកដាក់ហោង សព្វគ្រប់ម៉ត់ម៉ង ឥតមានភ្លេចអ្វីឡើយណ៎ា ។ កាំបិតកាន់ឲ្យគ្រប់គ្នា កណ្ដៀវផងវ៉ា យកមក សៀតក្នុងស្បូវហោង ។ រៀបស្រេចមកគិតគ្នាកង បាននរណាហោងនឹងជិះលើខ្នងបងខ្លា ។ អ្នកឆ្លាស់ឆ្លើយទៅវិញថា ឲ្យទន្សាយវា នោះវាគ្រាន់ជាអ្នកបរ ។ ទន្សាយនោះស្ដាប់ហើយអរ គេឲ្យអញបរ អញខ្ជិលដើរពេកណាស់ហោង ។ ទន្សាយគិតដូច្នោះជាម្ដង លោតឡើងលើខ្នង ខ្លានោះបរទៅឯងនែ ។ ទន្សាយបរទៅវ៉ៃ ៗ ឆ្ងាយបន្ដិចនែ ហើយយក ដែកភ្លើងមកវាយ ។ ឮតែច្រឹកៗ ពព្រាយខ្លាសួរទន្សាយ ថារ៉ុបងទន្សាយហ៎ា ។ ឮអ្វីច្រឹកៗសោះសា ទន្សាយឆ្លើយថា ចានវារណ្ដំនឹងគ្នា ។ ខ្លាជឿដើរទៅទៀតណ៎ា ទន្សាយនោះវា លូកយកដែកភ្លើងពីខ្នង ។ មកវាយទៀតតែបីដង ហើយ ឆេះជាម្ដង ប្រឹងផ្លុំឲ្យវាឆេះឆាប់ ។ ឆេះហើយវាដាក់ទៅផ្ទាប់ ខាងស្បូវប្រញាប់ ភ្លើងនោះផ្ទួចឆេះឡើងផង ។ ទន្សាយ លោតចេញជាម្ដង រត់ខ្ទាញ់ទៅហោង ទៅឡើងលើដើមសង្ឃ័រ ។ ផ្សាដោយខ្លួនភិតញញ័រ ឡើងទៅទទ័រ បេះផ្លែសង្ឃ័រ ស៊ីហោង ។ ឯខ្លានោះខ្លាំងកន្លង ដល់វាក្ដៅខ្នង រលាស់ខ្ទាត់ខ្ទាយចេញណា ។ ឯខ្នងរលោកក្ដៅផ្សា ចាប់ពើតពេកណា ស្រែកព្ររលូងទាំងព្រៃ ។ ក្នុងចិត្តខឹងណាស់ពេកក្រៃ នឹងទន្សាយនែ ខំរត់ទាំងឈឺតាមទៅ ។ វាស្រែករលូងពេកកូវ ខំ រត់តាមទៅ ទាន់ទន្សាយនៅសង្ឃ័រ ។ ផ្សាដោយចិត្តខឹងហើយ ឥឡូវនេះឯងហោងណ៎ា ។ អាចោរដកទងប៉ែអា អញ រកទេណ៎ា ឥឡូវអញឃើញហើយនែ ។ អញចាប់កាច់កឲ្យក្ស័យ ជីវិតហើយនែ សឹមអញទំពាលេចណ៎ា ។ ទន្សាយ ស្ដាប់ហើយឆ្លើយថា ជេរថាប៉ែអា ដកទងចង្រៃចោរលាញ ។ អញ្ជើញអាមកចាប់ទាញ អញទៅអម្បាញ បើថាខ្លួនអា មិនស្លាប់ ។ ទេពតាលោកចុះមកប្រាប់ឲ្យអញឡើងចាប់ បូតស្លឹកសង្ឃ័រស៊ីហោង ។ អញ្ជើញអាមកចាប់លង មិន ក្រែងជាម្ដង លោកជាទេពតានោះនែ ។ បើអាមិនមានទុក្ខភ័យ លុះដល់ខ្លួនក្ស័យជាងភ្លើងរលោកនោះណ៎ា ។ ក្រែង មិនជឿអញលងអា ចាប់អញស៊ីជា អាហារអានោះឯងនែ ។ បើអាមិនមានទុក្ខភ័យ ស្លាប់ហើយធ្លាក់ឮ នរកធូន់ជ្រៅ ក្ដាត់ណ៎ា ។ ខ្លាស្ដាប់ទន្សាយចរចារ ហាក់មែនដូចថា លោមវាម្ដងនេះឯងនែ ។ ក្សិណនោះឯខ្លាស្រដី ថានៃលេងអ្វី ទន្សាយអញចូលលេងផង ។ ទន្សាយស្ដាប់ជាក់ហើយហោង អញនៅជាម្ដង អានឹងមកស៊ីអញណ៎ា ។ ខ្លាស្ដាប់ ហើយឆ្លើយទេអា អញហ៊ានស្បថណ៎ា កុំឲ្យព្រះប្រោសអញហោង ។ ទន្សាយជឿខ្លាកន្លង ថាបើច្នោះហោង បងឯង ឡើងមកប្រញាប់ ។ បើបងឡើងមកចង់ស- ប្បាយបងបូតចាប់ អំពីគល់ឡើងខ្លាំងក្លា ។ ទន្សាយបង្គាប់នោះណ៎ា វា យល់បន្លា សង្ឃ័រនោះកោងចុះខ្មី ។ ទើបឯទន្សាយនោះនែ ប្រឹងប្រែងជើងដៃ លោតចុះបើកខ្លាឡើងទៅ ។ ទន្សាយរត់ ទៅសំដៅពានលើវល្លិនៅ វល្លិនោះជាតោងល្អក្រៃ ។ ឃើញហើយឡើងឆាប់វ៉ៃ ៗ អង្គុយលើនែហើយវាយោលជាទោង លេង ។ ឯខ្លានោះនៅតែឯង ឥតកោតឥតក្រែង បូកស្លឹកសង្ឃ័រលេងហោង ។ ទើបខ្លាក្ដាប់ខ្ទាប់ជាម្ដង បូកពីដើម ហោង វាមុតដៃនោះអស់ណ៎ា ។ ចាប់ពើតបង្អើតឈឺផ្សា លោតចុះដេញអា ទន្សាយរត់ខ្ទាញ់ទៀតទៅ ។ ដល់ឃើញ ទន្សាយនោះនៅ លើវល្លិនោះកូវ ថាអា ៗនៅនេះហើយ ។ អាបញ្ឆោតអញព្រងើយ អាមកកន្តើយ នៅនេះទេណ៎ាឯង នែ ។ អញដើររកងាពេកក្រៃ ឥឡូវនេះនែ ប្រទះនឹងអាហើយហោង។ ទន្សាយស្ដាប់ហើយឆ្លើយស្នង ជេរវិញរំពង ថា

អាធ្វើអ្វីអាចម៍អញ ។ ទេពតាទេព្រក្យស្រឡាញ់អញណ៎ាទើបអញ លោកឲ្យអញយោលទោងលេង ។ លោកយល់អញចេះកំប្លែង លោកឲ្យអញលេង លោកនឹងទ្រង់ព្រះសណ្ដាប់ ។រីឯអាខ្លានោះស្ដាប់ ជាក់ហើយក្រឡាប់ រំសាយខឹងនោះចេញ ។ អង្វរទន្សាយនោះវិញ ទន្សាយឲ្យអញយោលទោងលលេងផងរ៉ា ។ ទន្សាយថាអញឆោតណ៎ា អានឹងទំពា ក្បាលអញឥឡូវនេះឯង ។ ខ្លាថារុីអើយកុំក្រែង អញស្បថឲ្យឯង កុំឯងបារម្ភឡើយណ៎ា ។ ទន្សាយបានស្ដាប់ជឿប្រាកដហើយថាអា ឡើងមកយោលលេងចុះហោង ។ អញប្រាប់បងឯងជាម្ដង បងមានយោលលង បងយោលឲ្យខ្លាំងសោះសា ។ នោះទើបលោកទេពតា រឹងចូលចិត្តជា ស្រឡាញ់បងឯងពេកក្រៃ ។ ទន្សាយថាច្នោះវ៉ៃ ៗ ចុះមកដល់ដី ហើយខ្លាឡើងទៅយោលហោង ។ ទន្សាយរត់ខ្ចាញ់ជាម្ដង ឆ្ងាយក្រៃកន្លង ឃើញឫស្សីសង្កៀតគ្នា ។

នេះយើងស្រដីឯខ្លា វាយោលទោងណា ខ្លាំងឡើង ៗពេកក្រៃ ។ ដាច់វល្លិទោងនោះហើយនែ ធ្លាក់មកដល់ដី ដូចគេសសុកអស់អង្គ ។ មើលទៅភ្នែក ស្លើតស្លង់ ខំប្រឹងឈរត្រង់ កខ្វេសកខ្វាសមិងមាំង ។ យូរបន្តិចមានកម្លាំង រត់ទៅនឹងទាំង ផ្សាដោយចិត្តខឹងណាស់ណា ។ រត់ទៅបន្តិចឃើញអា ទន្សាយនោះណ៎ា នៅលើដើមឫស្សីហោង ។ ឃើញហើយថាអាដកទង អានៅនេះហោងអាស្លាប់ឥឡូវនេះនៃ ។ ទន្សាយស្ដាប់ហើយថាប៉ៃ អាចោរចង្រៃ អាឃើញអញធ្វើអម្បាញ់ ។ ទេពតាទេព្រក្យស្រឡាញ់ ទើបលោកឲ្យអញ លេងភ្លេងនៅនេះឯងហោង ។ លោកយល់អញចេះកន្លងត្រង់ភ្លេងភ្លាត់ផង នោះទើបលោកឲ្យលេងថ្វាយ ។ ខ្លាស្ដាប់ថាឱម៉ែអាយ មែនដឹងអ្នកអាយ ហាក់ជាពីរោះក្ដាត់ណា ។ ខ្លាលោមទន្សាយហើយថា រុីអើយឲ្យគ្នា លេងផងនឹងឯងបានទេ ។ ទន្សាយស្ដាប់ហើយថាមេ អញមិនឆោតទេ ឯងមកនឹងខាំអញនៃ ។ ខ្លាស្ដាប់ជាក់លាក់ថា ហៃនៃរុីកុំភ័យ អញមិនចងទោសឡើយណា ។ អញស្បថឲ្យលោកអ្នកតាកាច់អញណ៎ា ឥឡូវនេះឯងពិតហោង ។ ទន្សាយស្ដាប់ជាក់ជាម្ដង បើច្នោះចូរបង ខ្លាឯងឡើងមកចុះណ៎ា ។ អញចង់នឹងផ្ដាំបងខ្លា ត្បិតអញនេះណ៎ា លេងភ្លេងពីរោះប៉ុណ្ណោះ ។ បើបងមកលេងភ្លេងនេះ ក្រែងបងមិនចេះ អញប្រាប់បងឯងឲ្យជាក់ ។ ដល់ខ្យល់បក់មករអាក់ កន្ទុយដាក់ ក្នុងឈើសង្កៀតនោះហោង ។ រឹងជាពីរោះកន្លង លើសលែងអញហោង ទេពតារឹងជាស្រឡាញ់ ។ ទន្សាយផ្ដាំហើយ រត់ខ្ចាញ់ ដូចគេត្របាញ់ ទៅឆ្ងាយនោះពេកណាស់ហោង ។ ពានលើឱម៉ាល់ធំផង វាដេកថ្ងៃហោង បេះយកស្លឹកឈើចុករន្ធ ។ ចុកស្រេចហើយវាអរលន់ យកដៃវាទន់ ទះវាយធ្វើភ្លេងជាល្បែង ។ ឯមេឱម៉ាល់នោះឯង ផ្អើលក្នុងក្រៃលែង វាចេញមិនរួចសោះសា ។ ពោលនោះទន្សាយនោះវា ទះលេងមហិមា ឮតែកន្រ្ទុបអ្វីៗ ។

រីឯខ្លានោះមូទូ ស្រដីអ្វូ ៗ ធ្វើតែម្នាក់ឯងហោងណ៎ា ។ ឡើងទៅធ្វើដូចពាក្យអា ទន្សាយនោះណា ដល់ខ្យល់បក់មកនោះនៃ ។ យកកន្ទុយដាក់រ៉ៃ ៗ វាតឿៀតខ្លាំងក្រៃ ស្រែករោទ៍រំពងសោះសា ។ ស្ទុះស្ទែងខះខែងតក្កមា រួចហើយម៉្នីម្នា លោតចុះចេញទន្សាយទៀត ។ រត់តាមទៅដល់បៀតឃើញ ទន្សាយទៀត ហើយស្រែករំពងទៅថា ។ អាចោរនៅនេះហើយណ៎ា ស្ដាប់ម្ដងនេះប្រា- កដឯងមិនទេឡើយនៃ ។ ទន្សាយបែរហើយស្រដី ស្លាប់អាចម៍អញនៃ ធ្វើម្ដេចអានឹងបានអញ ។ ទេពតាទេព្រក្យស្រឡាញ់ ទើបលោកឲ្យអញ លេងភ្លេងថ្វាយលោកប្រក្រតី។ ខ្លាស្ដាប់ហើយធ្វើថារុីគ្នាលេងផងរុី គ្រាន់បានជាពីរនាក់ណ៎ា ។ ទន្សាយស្ដាប់ហើយឆ្លើយថា អញឆោតឲ្យអា មកហើយអានឹងខាំអញ ។ ខ្លាថាទេរុីយសម្លាញ់ គ្នាមិនច្នោះមិញ នោះគ្នាហ៊ានស្បថនឹងឯង ។ ត្រង់ចិត្តខឹងនោះគ្នាលែង ចេញហើយកុំក្រែង រអែងត្រង់នេះឡើយណ៎ា ។ ទន្សាយជឿហើយហៅថា មកចុះបងខ្លា ឡើងមកអញផ្ដាំបងឯង ដល់បងនឹងវាយ ជា

ភ្លេង បងវាយកុំក្រែង រអែងខ្លាចអ្វីឡើយណ៎ា ។ ដៃបងធ្ងន់ក្រៃមហិមា វាយឲ្យខ្លាំងណ៎ា នោះរឹងជាពីរោះហោង ។ ទន្សាយភិតភ័យកន្លង រត់មើលក្រោយហោង ស្រាប់តែធ្លាក់ក្នុងអណ្ដូង ។ ឯខ្លាយកដៃទះផ្ទង ឮតែតូង ៗ ធ្លាយសំបុកឪម៉ាល់ណា ។ វារោមចោមខ្លាំងមហិមា ខ្លាលោតស្រែកថា ម៉ែអើយអញស្លាប់នេះម្ដង ។ ហើយស្រែកយំកងរំពង ខ្លាំងក្រៃពេកហោង ស្ទុះលោតស្ទើរតែមិនទាន់ ។ ចុះមកដល់ដីវាកាន់ តែឈឺរន្ធាន់ ពើតចាប់រមូលមែនមួន ។ ឈឺចាប់ញ័រអស់ទាំងខ្លួន ខ្លាំងក្រៃផ្ទួនៗ ពីព្រោះទ្រនិចច្រើនណាស់ ។ លុះស្រាកគ្រាន់បន្តិចច្បាស់រត់តាមរហ័ស ទន្សាយនោះទៅទៀតហោង ។ តាមបន្តិចទៅជាម្ដង ឃើញទន្សាយហោង ធ្លាក់ក្នុងអណ្ដូងនោះណ៎ា ។ ស្រមៀន អៀនប្រៀនឃើញខ្លាមុខដូចខ្មោចណ៎ា មមីសក្នុងអណ្ដូងខ្មី ។ ខ្លាឃើញធ្លាក់ហើយស្រដី អាណានេះវ៉ី អាស្លាប់ម្ដងនេះឯងណ៎ា ។ ទន្សាយថាវ៉ីប៉ែអា គិតឯងអញណ៎ា អញនៅក្នុងអណ្ដូងហោង ។ គិតតែអាឯងជាម្ដង នៅលើនោះហោង ក្រែងមេឃរលំសង្កត់ ។ ល្អិតដូចគេបែនគេបត់ បាក់ឆ្អឹងខ្ទេចម៉ដ្ឋ ក្សិណក្ស័យជីវិតមរណហោង ។ ខ្លាស្ដាប់ហើយគិតកន្លង ភ័យណាស់ជាម្ដង លោតចុះក្នុងអណ្ដូងណ៎ា ។ ត្រូវជាពីរនាក់នឹងខ្លា ទន្សាយនោះណ៎ា ស្រមៀនក្នុងអណ្ដូងហោង ។ ទន្សាយគិតឯងកន្លង ធ្វើម្ដេចអញ ហោង នឹងបានឡើងរួចទៅលើ ។

ទន្សាយរកកលកិច្ចធ្វើ នឹងខ្លាចាក់មើល ចង់ឲ្យខ្លាចាប់ចោលទៅ ។ គិតច្នោះយកដៃនោះកូរ ចាប់ខ្លានោះត្រូវចង្កេះខ្លាលោតប៉ផ្លោត ។ ខ្លាថាអាចោរគេដោត អាខូចកញ្ឆោត ម្ដេចមិនគិតខ្លួននឹងស្លាប់ ។ បើឥតគំនិតអញចាប់បោះឡើងលើឆាប់នឹងស្លាប់មេឃរលំហោង ។ ទន្សាយនឹងអរកន្លង ពានចំណុចផង រឹងជាចាក់ណាស់សោះសា ។ ខ្លាខឹងច្រើនដងច្រើនគ្រា អត់ពុំបានណ៎ា ក៏ចាប់ទន្សាយចោលព្រួច ។ ទន្សាយថាឱអញរួច នឹកអរព្រួច ៗ អញបានរួចពីទុក្ខហោង ។ ទើបទន្សាយស្រែករំពង ហោងអ្នកស្រុកផង ឲ្យមកចាក់ចាប់ខ្លាព្រៃ ។ វាធ្លាក់ក្នុងអណ្ដូងនែ អ្នកអើយវ៉ៃ ៗ យកដាវលំពែងនិងស្នា ។ ឯឆ្កែកុំយកមកណ៎ា យកតែធ្នូស្នា លំពែងកាំភ្លើងនោះហោង ។ ទន្សាយគិតពេកកន្លង កុំយកឆ្កែហោង នោះក្រែងឆ្កែខាំខ្លួនវា ។ ទន្សាយប្រាប់គេហើយណ៎ា រួចរត់ទៅប្រាកដឆ្ងាយណាស់ពេកកន្លង ។ រីអស់អ្នកស្រុកអឺងកង ហៅគ្នារំពង ឲ្យយកកាំភ្លើងធ្នូស្នា ។ ហើយនាំគ្នាដើរម្នីម្នា កាន់គ្រឿងគ្រប់គ្នា មកចាក់ខ្លានោះស្លាប់ហោង ។

**កម្លាំងកាយទុកថាគ្រាន់បើ ក៏មិនស្មើកម្លាំងប្រាជ្ញា**